**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា**


**ប្រធានគណៈមេធាវី**

មេធាវី ប៊ុន ហុន

**ក្រុមប្រឹក្សាគណៈមេធាវី**

១-មេធាវី សាំង ចន្ថារ:

២-មេធាវី អ៊ុំ គិរិយា

៣-មេធាវី កែត ឃី

៤-មេធាវី អ៊ីវ ប៉ូលី

៥-មេធាវី ខៀវ សំបូរ

៦-មេធាវី ជា សុកន្ធន

៧-មេធាវី សាន់ ជួយ

៨-មេធាវី ថាន ផានិត

៩-មេធាវី ជូ ចាន់ធីរ៉ា

១០-មេធាវី កេង សុម៉ាឡា

១១-មេធាវី ម៉ី ឧសភា

១២-មេធាវី សេង សុខឃីម

១៣-មេធាវី លីវ សុវណ្ណា

១៤-មេធាវី ឈីវ គិរម្យ

១៥-មេធាវី សំ សុគង់

១៦-មេធាវី នង មានន្ទ

១៧-មេធាវី អ៊ូ ធីតាពៅ

១៨-មេធាវី លី ពីង

១៩-មេធាវី យឹម វិសុទ្ធ

២០-មេធាវី លីម ច័ន្ទលីដា

២១-មេធាវី កែ វិសាល

២២-មេធាវី ហូ លីហួច

២៣-មេធាវី វ៉ា ពិសី

២៤-មេធាវី ជា ហុងរី

២៥-មេធាវី សៅ កញ្ញា

២៦-មេធាវី ម៉ុន វិមានចំប៉ា

២៧-មេធាវី ឈី សម្បត្តិ


លេខ : ០៧៩ /សសគម/១៦

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០១៦

# សេចក្ដីសម្រេច

## ស្ដីពី

## ការអនុញ្ញាតឱ្យប្ដូរគ្រូកម្មសិក្សា

## ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ស្ដីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **ប៊ុន ហុន** ជាប្រធានគណៈមេធាវីអាណត្តិទី ១០
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៨
- បានឃើញសេចក្ដីសម្រេចលេខ ៣៧៦/សសគម/១៥ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ របស់គណៈមេធាវី ស្ដីពីការអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈជាមេធាវីកម្មសិក្សា
- យោងតាមសំណើរបស់សាមីខ្លួន ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៦។

## ស ម្រេ ច

**ប្រការ ១.-** អនុញ្ញាតឱ្យលោកមេធាវី **ម៉ន ឧត្ដម** អត្តលេខ **១១០៧ T** ប្ដូរគ្រូកម្មសិក្សាពីលោកមេធាវី **ហួន សុភ័ក្ត្រ** មកលោកមេធាវី **ណុន វ៉ាន់ណេត** វិញ ដែលមានការិយាល័យឈ្មោះ **ក្រុមមេធាវី នីតិរដ្ឋ** មានអាសយដ្ឋានស្ថិតនៅ**ផ្ទះលេខ ១០-B2E$_0$E$_1$ ផ្លូវលេខ ២១១ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ** ចាប់ពីថ្ងៃចេញសេចក្ដីសម្រេចនេះតទៅ។

**ប្រការ ២ .-** - រាល់ទំនាក់ទំនង និង គ្រប់លិខិតរបស់កម្មសិក្សាការី ដែលធ្វើឡើងក្នុងក្របខ័ណ្ឌប្រកបវិជ្ជាជីវៈរបស់ខ្លួន ត្រូវមានហត្ថលេខាយល់ព្រមពីគ្រូកម្មសិក្សា។

- គ្រប់ការងារកម្មសិក្សារបស់កម្មសិក្សាការី ស្ថិតនៅក្រោមការគ្រប់គ្រង និងទទួលខុសត្រូវផ្ទាល់របស់គ្រូកម្មសិក្សា។

- ចប់រយៈពេលកម្មសិក្សា កម្មសិក្សាការី ត្រូវធ្វើរបាយការណ៍អំពីលទ្ធផលការងាររបស់ខ្លួន ដោយភ្ជាប់មកជាមួយនូវឯកសារសំអាងទាំងអស់ សម្រាប់ដាក់ជូនក្រុមប្រឹក្សាគណៈមេធាវី ពិនិត្យ និងសម្រេច។

**ប្រការ ៣ .-** របាយការណ៍បញ្ចប់កម្មសិក្សាក្នុងរយៈពេលពី**ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ រហូតដល់ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦** ត្រូវមានការបញ្ជាក់ពីគ្រូកម្មសិក្សាចាស់ (លោកមេធាវី **ហួង សុភ័ក្រ្ត**) ហើយចាប់ពីថ្ងៃទី**០៦ ខែមិថុនា ឆ្នាំ២០១៦** រហូតដល់ចប់កម្មសិក្សា ត្រូវមានការបញ្ជាក់ពីគ្រូកម្មសិក្សាថ្មី (លោកមេធាវី **ណុន វ៉ាន់ណេត**)។

**ប្រការ ៤ .-** បទប្បញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥ .-** អគ្គលេខាធិការ អគ្គហេរញ្ញិក និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមមុខការរៀងៗខ្លួន៕

**មេធាវី.ប៊ុន-ហុន**

**ចម្លងជូន :**

-ក្រុមប្រឹក្សាគណៈមេធាវី

-លោកមេធាវី **ហួង សុភ័ក្រ្ត**

-លោកមេធាវី **ណុន វ៉ាន់ណេត**

-ដូចប្រការ ៥

-ឯកសារ-កាលប្បវត្តិ